# បទល្មើស

.ចោរកម្ម

.ជួញដូរគ្រឿងញៀន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

**************

សាលាឧទ្ធរណ៍ភ្នំពេញ

សំណុំរឿងព្រហ្មទណ្ឌ

លេខ: ២៥៦ / ២៤.៦.២០០២

សាលដីកា

លេខ: ១១៩ «ខ»/ ០៥.៩.២០០៧

## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី០៥ ខែកញ្ញា ឆ្នាំ២០០៧ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

ឯកឧត្តម [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ២៥៦ ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០២ រវាង ៖

១. ជនជាប់ចោទឈ្មោះ[redacted]តនា ហៅ ពៅ ចាន់ថន ភេទប្រុស អាយុ៤២ឆ្នាំ ជាតិខ្មែរ មុខរបរៈធ្វើពេទ្យ កើតនៅ ភូមិត្រពាំងខ្លង ឃុំបាទី ស្រុកចាន់ទ្រា ខេត្តស្វាយរៀង លំនៅមុន[redacted] ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោ[redacted] (ស) ម្តាយឈ្មោះ [redacted](ស) ប្រពន្ធឈ្មោះ[redacted] មានកូន៤នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ ឃុំខ្លួនថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩។

មានមេធាវីការពារលោក [redacted]ពិសិដ្ឋ។

២. ជនជាប់ចោទឈ្មោ[redacted]ធាន់ ភេទប្រុស អាយុ២៦ឆ្នាំ ជាតិខ្មែរ មុខរបរៈកងរាជអាវុធហត្ថ ទីលំនៅកំណើត និងទីលំនៅមុនចាប់ខ្លួន ភ[redacted]ា ស្រុកបារាយណ៍ ខេត្តកំពង់ធំ ឪពុកឈ្មោះ [redacted](ស) ម្តាយឈ្មោះ [redacted]) ប្រពន្ធឈ្មោះ [redacted]មានកូន០១នាក់ (លែងលះ) ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩ ឃុំខ្លួនថ្ងៃទី២៤ ខែសីហា ឆ្នាំ១៩៩៩។

មានមេធាវីការពារលោក ម៉ៅ សារី។

ជាប់ចោទពីបទៈ អំពើភេរវកម្ម ប្រព្រឹត្តនៅ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ ភេទប្រុស អាយុ៣៨ឆ្នាំ ជាតិខ្មែរ មុខរបរៈលក់ដូរ បច្ចុប្បន្នរស់នៅ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ។ ត្រូវជាឪពុករបស់សពកុមារ [redacted] ស្រស់។

**៦ដំណើររឿងមានដូចតទៅ ៖**

នៅថ្ងៃកើតហេតុ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ ឈ្មោះ[redacted] ធាន់ ជាឪពុកមា បានចាប់ក្មួយប្រុសឈ្មោះ [redacted] ស្រស់ អាយុ១២ឆ្នាំ ពីក្រោមផ្ទះ ស្ថិតនៅភូមិថ្នល់ជាតិ រួមមានឈ្មោះ[redacted] រតនា ហៅ[redacted] ចាន់ថន, ឈ្មោះ សឿន, ឈ្មោះ ហៀប និងឈ្មោះ រី ។ ឈ្មោះ[redacted] ពៅ ជាឪពុកក្មេងត្រឡប់មកពីភ្នំពេញ មិនឃើញកូន គិតថាកូននៅផ្ទះម្តាយធំវា មិនចាប់អារម្មណ៍រកទេ។ លុះព្រឹកឡើង ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៩៩ ឃើញសំបុត្រ១ ទើបដឹងថាកូនប្រុសត្រូវគេចាប់ខ្លួន ដើម្បីជំរិតយកប្រាក់ចំនួន ១.៥០០$, ហើយបានធ្វើការលោះកូនយកមកវិញ តែឈ្មោះ[redacted] ធាន់ បានប្រើល្បិចផ្ទាល់ខ្លួន រួមជាមួយឈ្មោះ[redacted] រតនា ហៅ ចាន់ថន ព្រមទាំងឈ្មោះ សឿន, ឈ្មោះ ហៀប និងឈ្មោះ រី បង្គាប់យកប្រាក់ចំនួន ៨០០$ បន្ថែម ប៉ុន្តែ ឈ្មោះ [redacted] ពៅ អង្វរឲ្យត្រឹមតែ ៦០០$ ហើយក៏បែកការណ៍ ឈ្មោះ [redacted] ធាន់ និងឈ្មោះ[redacted] រតនា ប្រគល់ប្រាក់ឲ្យវិញ ចំណែកក្មេងរងគ្រោះឈ្មោះ[redacted] ស្រស់ បាត់ខ្លួនរហូត។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ធំ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- សម្រេចបង្អង់បណ្តឹងអាជ្ញាលើឈ្មោះ សឿង ១, ហៀប ១ និងឈ្មោះ រី ដោយគ្មានសាវតាជាតិ។

២- ផ្តន្ទាទោសៈ

- ឈ្មោះ[redacted] រតនា ហៅ ពៅ ចាន់ថន អាយុ៤២ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារអស់មួយជីវិត
- ឈ្មោះ[redacted] ធាន់ អាយុ២៦ឆ្នាំ ភេទប្រុស ជាតិខ្មែរ ដាក់ពន្ធនាគារអស់មួយជីវិត ពីបទ អំពើភេរវកម្ម ប្រព្រឹត្តនៅ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសដែលមានបញ្ញត្តិឲ្យផ្តន្ទាទោសតាមមាត្រា ២ នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

ទោសខាងលើនេះ គិតពីថ្ងៃចាប់ខ្លួនតទៅ។

៣- សម្រេចឲ្យឈ្មោះ[redacted] រតនា ហៅ[redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ រួបរួមគ្នាសងសំណងជាប្រាក់ចំនួន ១.៥០០$ (មួយពាន់ប្រាំរយដុល្លាអាមេរិក) និងជួសជុលជម្ងឺចិត្តជាប្រាក់ចំនួន ៣.០០០.០០០៛ (បីលានរៀល) ឲ្យទៅឈ្មោះ[redacted] ពៅ ជាដើមបណ្តឹងរដ្ឋប្បវេណី, បណ្តឹងទាមទារលើសពីនេះ បដិសេធចោល,

ក្នុងករណីទណ្ឌិត [redacted] រតនា ហៅ[redacted] ចាន់ថន និង [redacted] ធាន់ រឹងទទឹងមិនព្រមសង[illegible]នេះ

ទេ ត្រូវដាក់គុកបង្ខំដល់រូបកាយ តាមមាត្រា ៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៤- សាលក្រមនេះ ជំនុំជម្រះជាសាធារណៈ ប្រកាសចំពោះមុខគូក្តី និងមេធាវី។ ទុកសិទ្ធិឲ្យគូភាគី ប្តឹងឧទ្ធរណ៍ ក្នុងកំណត់ច្បាប់ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ធំ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច ។

បានឃើញ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ ។

បានឃើញ របាយការណ៍រឿងរបស់ចៅក្រមសាលាឧទ្ធរណ៍ ។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ បានឆ្លើយនៅតុលាការខេត្តកំពង់ធំ។

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ពៅ បានឆ្លើយនៅតុលាការខេត្តកំពង់ធំ។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

១- ទទួលបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២- តម្កល់សាលក្រមព្រហ្មទណ្ឌរបស់តុលាការខេត្តកំពង់ធំ ទុកជាបានការដដែល។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

លោក [redacted] សារី មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] ធាន់ សន្និដ្ឋានថាៈ ក្នុងរឿងនេះដើមបណ្តឹងឈ្មោះ [redacted] ពៅ បានចោទកូនក្តីខ្លួន នៅពេលដែលមានពាក់ព័ន្ធរឿងលុយ តែក្រោយមកកូនក្តីខ្លួនបានយកប្រាក់ទាំងនោះប្រគល់ឲ្យដើមបណ្តឹងវិញហើយ សូមលោកប្រធានពិចារណា និងសូមលើកលែងចោទប្រកាន់កូនក្តីខ្លួនដោយអនុគ្រោះ។

លោក [redacted] រ៉ាពិសិដ្ឋ មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] រតនា សន្និដ្ឋានថាៈ ក្នុងរឿងនេះ នៅពេលកើតហេតុ កូនក្តីខ្លួនមិនបានដឹងរឿងទេ ទាល់តែឪពុកជនរងគ្រោះបានមកពឹងពាក់កូនក្តីខ្លួន នៅពេលឃើញសំបុត្ររបស់ក្រុមចោរចាប់ជម្រិត ហើយបានយកប្រាក់ចំនួន១.៥០០$ តាមសំបុត្រ ទៅឲ្យក្រុមចោរចាប់ជម្រិត ហើយនៅពេលយកប្រាក់ ទៅដាក់នៅកន្លែងដែលក្រុមចោរចាប់ជម្រិតបានកំណត់នោះហើយ ក្រុមចាប់ជម្រិតនៅតែមិនព្រមប្រគល់កុមាររងគ្រោះត្រឡប់មកទេ, ក្រោយពីមានការតថ្លៃ ហើយព្រមព្រៀងបន្ថែមក្នុងតម្លៃ ៨០០$ តែកូនក្តីខ្លួនសុំឲ្យក្រុមចាប់ជម្រិតដោះលែងជនរងគ្រោះជាមុន ទើបព្រមប្រគល់ប្រាក់ តែជនចាប់

ជម្រិតមិនបានលែងជនរងគ្រោះទេ កូនក្តីខ្លួនក៏បានយកប្រាក់នោះមកប្រគល់ឲ្យដើមបណ្តឹងឈ្មោះ [redacted] ពៅ វិញ, សូមលោកប្រធានក្រុមប្រឹក្សាមេត្តាធ្វើការលើកលែងចោទដល់កូនក្តីខ្លួន និងសូមធ្វើការដោះលែងកូនក្តីខ្លួនជាបន្ទាន់។

ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ,

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី,

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវី

ក្រោយពីបានពិភាក្សា ជែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងឧទ្ធរណ៍ លេខ១៧ ចុះថ្ងៃទី២០-ខែមេសា ឆ្នាំ២០០០ របស់ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ ធ្វើឡើងនៅក្នុងកំណត់ច្បាប់ សាលាឧទ្ធរណ៍ទទួលជំនុំជម្រះតាមមាត្រា ១៧៨ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ។

២. ជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន បានឆ្លើយថា ខ្លួនស្គាល់ពួកចាប់ជំរិត គឺឈ្មោះ រី និងឈ្មោះ ហៀប ហើយខ្លួនជាអ្នកឲ្យប្រពន្ធខ្លួនសរសេរសំបុត្តអានាមិកផ្ញើឲ្យឈ្មោះ [redacted] ពៅ ជាឪពុកកុមារ [redacted] ស្រស់ ជាជនរងគ្រោះ ដើម្បីឲ្យយកប្រាក់ទៅលោះកូន។

ចំណែកជនជាប់ចោទឈ្មោះ [redacted] ធាន់ ឆ្លើយថា កាលពីថ្ងៃ-ខែ មិនចាំ ឆ្នាំ១៩៩៩ វេលាម៉ោង២រសៀល ខ្លួនកំពុងបេះត្រកួនមានមនុស្សបីនាក់ជិះរថយន្តម៉ាកកាមរី ទៅឈប់មុខផ្ទះឈ្មោះ ហឿន ហើយម្នាក់ចុះពីឡានទៅចាប់ដៃក្មេងទាញឡើងឡាន រួចចង្អុលមុខខ្លួន, លុះម៉ោង៧យប់ មានមនុស្សបិទមុខម្នាក់កាន់កាំភ្លើងមកភ្ជង់ខ្លួនគំរាមឲ្យសរសេរសំបុត្រឲ្យឈ្មោះ [redacted] ពៅ ជាឪពុកកុមាររងគ្រោះឈ្មោះ [redacted] ស្រស់ បង្គប់ឲ្យយកប្រាក់ចំនួន ១.៥០០ដុល្លាអាមេរិក ទៅដាក់ដើមត្នោតក្រោយផ្ទះ តំបន់ពោធិ៍តូច, ខ្លួនស្គាល់សំឡេងច្បាស់ ជននោះ គឺគ្រូ [redacted] រតនា។ ខ្លួនក៏សរសេរសំបុត្របិទស្រោម យកទៅបោះនៅមុខផ្ទះ [redacted] ពៅ ទាំងយប់នោះ។ លុះស្អែកឡើង ខ្លួន និងគ្រូ ចាន់ថន យកប្រាក់ ១.៥០០ដុល្លាអាមេរិក ទៅឲ្យក្រុមចោរ តែមិនសម្រេច, ខ្លួនក៏សរសេរសំបុត្រដោយផ្ទាល់ដៃជាលើកទី២ បិទស្រោមយកទៅទម្លាក់តាមចិញ្ចើមថ្នល់ រួចធ្វើជារើសលិខិតនោះឲ្យទៅឈ្មោះ ខ្នា ឲ្យយកទៅឲ្យឈ្មោះ [redacted] ពៅ។ ហើយបញ្ជាក់ថា ខ្លួនសរសេរសំបុត្រយកទៅឲ្យឈ្មោះ [redacted] ពៅ លើកទី១ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ១៩៩៩ វេលាម៉ោង៨យប់, លើកទី២ នៅថ្ងៃទី០២ ខែកក្កដា ឆ្នាំ១៩៩៩ វេលាម៉ោង៨យប់ដែរ។

៣. មានពិរុទ្ធលើជនជាប់ចោទឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ ពីបទ អំពើ

ភេរវកម្ម ប្រព្រឹត្តនៅ ភូមិថ្នល់ជាតិ ឃុំបារាយណ៍ ស្រុកបារាយណ៍ ខេត្តកំពង់ធំ កាលពីថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៩៩ បទល្មើសព្រហ្មទណ្ឌមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ២ (កថាខណ្ឌ២) នៃច្បាប់ស្តីពីការផ្តន្ទាទោសអំពើភេរវកម្ម។

៤. តុលាការថ្នាក់ក្រោមបានលើកយកភស្តុតាង និងសំអាងហេតុមកបង្ហាញ និងបញ្ជាក់ច្បាស់លាស់ត្រឹមត្រូវគ្រប់សព្វហើយ សាលាឧទ្ធរណ៍មិនចាំបាច់លើកយកភស្តុតាង និង សំអាងហេតុដដែលនោះ មកបង្ហាញ និងបញ្ជាក់ឡើងវិញទៀតទេ។

៥. សាលក្រមព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ធំ សម្រេចត្រឹមត្រូវតាមច្បាប់ គួរតម្កល់ទុកជាបានការ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងឧទ្ធរណ៍លេខ ១៧ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០០ របស់ជនជាប់ចោទ ឈ្មោះ [redacted] រតនា ហៅ [redacted] ចាន់ថន និងឈ្មោះ [redacted] ធាន់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២. តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ២៣ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០ របស់តុលាការខេត្តកំពង់ធំ ទុកជាបានការ ពេញទាំងមូល។

៣. សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

**សាលដីកានេះចូលជាស្ថាពរ មានអានុភាពអនុវត្តតែលើឈ្មោះ [redacted] ធាន់ ក្រៅពីនោះ ពុំមានអានុភាពអនុវត្តឡើយ។**

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] | ហត្ថលេខា: [redacted] |

បានឃើញ

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម

ភ្នំពេញ ថ្ងៃទី [illegible] ខែ កុម្ភៈ ឆ្នាំ ២០១៤

**ក្រឡាបញ្ជី**

[redacted]